# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0010**

សម្ភាសន៍ជាមួយៈ ព្រំ សុឃឿន ហៅ ផូ ហាប់ អាយុ៥៦ឆ្នាំ ភេទប្រុស

មុខងារខ្មែរក្រហមៈ ជាអ្នកសែនជី

មុខងារបច្ចុប្បន្នៈ ធ្វើស្រែ

ស្រុកកំណើតភូមិផ្លូវបំបែក ឃុំកំពង់ត្រាច ស្រុកកំពង់ត្រាច ខេត្តកំពត

សព្វថ្ងៃរស់នៅភូមិត្រសេកជ្រុំ ឃុំមាំឡៃ ស្រុកមាំឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០១:០១:២០

សរុបទំព័រៈ ២៤

ដានី ៖ បាទ!ដឹបូនខ្ញុំសុំស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

ឃឿន ៖ ខ្ញុំឈ្មោះ ព្រំ សុឃឿន។

ដានី ៖ ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ឃឿន ៖ អាយុ៥៦

ដានី ៖ ស្រុកកំណើតពូនៅណាដែរ?

ឃឿន ៖ ស្រុកកំណើតនៅស្រុកកំពង់ត្រាច ខេត្តកំពត

ដានី ៖ ភូមិអីដែរ?

ឃឿន ៖ ភូមិផ្លូវបំបែក ឃុំកំពង់ត្រាច ស្រុកកំពង់ត្រាច ខេត្តកំពត

ដានី ៖ ឪពុកម្ដាយពូឈ្មោះអីទៅ?

ឃឿន ៖ ឪពុកម្ដាយខ្ញុំស្លាប់អស់ហើយស្លាប់តាំង៧៩

ដានី ៖ គាត់ស្លាប់ដោយសារមូលហេតុអីដែរ?

ឃឿន ៖ ខ្ញុំអត់ដឹងដែរ ខ្ញុំចេញបែកពីគាត់ ដឹជួបប្អូនៗក្រោយថាគាត់ឈឺស្លាប់

ដានី ៖ គាត់ឈ្មោះអីដែរ?

ឃឿន ៖ ឪពុកខ្ញុំឈ្មោះ ភរ ស៊ិន ម្ដាយឈ្មោះ ព្រំ យុន

ដានី ៖ ម្ដាយឈ្មោះ ព្រំ យុន ឪពុកឈ្មោះ ភរ ស៊ិន ពូយកត្រកូលតាមម្ដាយវិញ?

ឃឿន ៖ បើមិនយកត្រកូលជំនាន់ហ្នឹងគេថាយើងចេះចុះ ហើយរាជខ្ញុំកាលហ្នឹងវារាជឡូអ្នកផ្សារផង គេថាខ្វាចចិនខ្វាចអី គេប្រុងយកខ្ញុំទៅវៃចោលម្ដងហើយហ្នឹង គេថាខ្ញុំកូនសក្តិភូមិនាយទុន

ឯណាចេះចុះ ដឹងអញ្ចឹងទៅខ្ញុំនឹកឃើញថាមិនកើតទេ បើសិនជាយកត្រកូលខ្ញុំអត់កើត ហើយខ្ញុំក៏ដាក់ឈ្មោះត្រកូលម៉ែខ្ញុំវិញទៅ ។

ដានី ៈ ចុះឈ្មោះពូ ឈ្មោះកាលនៅរៀន?

យឿន ៈ ហ្នឹងឈ្មោះ ភរ ហ៊ាប់

ដានី ៈ ចុះពូប្រែឈ្មោះពេលណាព្រាំ សុយឿន ហ្នឹង?

យឿន ៈ មកប្រែនៅឆ្នាំ១៩៧៥ ពេលចូលកងចល័តៗគេដកខ្ញុំម៉ាកន្លែងទៅម៉ាកន្លែង គេចេះតែគាប់សួរខ្ញុំថាឯងកូនសក្តិភូមិនាយទុនហ្នឹង ហើយខ្ញុំថាខ្ញុំអត់ទេ ក៏ទាញខ្ញុំឲ្យចូលកងជី កងសែងអាច់ គេថាវាងហែងសមតែអ្នកសែងអាច់បានត្រូវ ពីមុនហែងសុខស្រួលណាស់ ដាក់ឲ្យទូលនៅសែងអាច់ ។

ដានី ៈ ចុះពូមានបងប្អូនប៉ុន្មាននាក់ដែរ?

យឿន ៈ ខ្ញុំបងប្អូនខ្ញុំ៦នាក់ ប្រុស៥ ស្រី១

ដានី ៈ អញ្ចឹងប្រុស៥ ស្រី១ ទាំងអស់៦នាក់ ស្រីនោះពៅគេ ពូកូនទី២?

យឿន ៈ ខ្ញុំបើគិតនៅក្នុងម្តាយខ្ញុំនេះខ្ញុំកូនទី២ តែមានបងស្រីមួយគាត់នៅអាមេរិច ឥឡូវគាត់ស្លាប់បាត់ហើយហ្នឹងគាត់កូនម្តាយមុន រស់មែនទែនដល់រហូតម៉ោចេះតែម៉ោតាមគេទៅ គេចេះតែញុះញង់ថាអ្ហូហែងតែម៉ោវិញយួនអ៊ីវក អញ្ចឹងខ្ញុំចេះតែម៉ោតាមគេរហូតម៉ោដល់ឆ្នាំ៧៩ហ្នឹងគេបំពាក់អាវុធឲ្យ ហ្នឹងហើយគេបំពាក់អាវុធឲ្យហើយចេះតែនៅទ័ពគេរហូតទៅ គេប្រើទៅណាក៏ចេះទៅ បើយើងមិនដឹងទៅទៀតទៅក្នុងគេថាយួនអ៊ីវក អញ្ចឹងចេះតែទ្រាំនៅ ប៉ុនទាស់ការរស់នៅមិនជាយ៉ាប់ទេ ប៉ុនទាស់តែវាខ្វះខាតការហូបចុះអញ្ចឹងណាស់ ជួនណាដូចពួកខ្ញុំនេះម៉ាកងតូចមួយពេល៣អង្ករកំប៉ុង គ្នា៣៣នាក់មួយពេលអង្ករ៣កំប៉ុង បបរអត់ឃើញគ្រាប់អង្ករទេ ឃើញតែបន្លែ ហើយគេប្រើឲ្យទៅវ៉ៃ ទៅឆ្ពក់ទៅឆ្មក់ទៅដាក់មីនអឿចេះតែទៅៗទៅរហូតដល់ចុង៧៩ ៗ បានធូរធារហើយ តាំងពីយួនវ៉ៃបំបែកផ្លូវបន្ទាយជួរព្រំដែនធ្លាក់ទៅដីថៃអស់ហ្នឹងសំបូរហូបវិញ ។

ដានី ៈ ម៉េចអញ្ចឹង?

យឿន ៈ វាសំភារៈវានៅម៉ោអត់ទាន់ដល់នោះកាលហ្នឹង ឬមួយក៏គេកុហកមិនដឹងទេកាលហ្នឹង គេថាអត់ទាន់បញ្ជូនម៉ោៗគេឲ្យស៊ីសន្សំសំចៃសិនទៅ អញ្ចឹងមិនដឹងប្រកែកម៉េច ដល់ពេលយួនវ៉ៃបំបែកនេះអស់ ធ្លាក់ទៅដីថៃនេះអាហ្នឹងសំភារៈធ្លាក់មកសព្វបែបយ៉ាងមិនខ្វះទេកាលហ្នឹង ឃើញជំនួយម៉ោកាណាដា ម៉ោពីជប៉ុន ម៉ោពីអាមេរិច គ្រប់កន្លែងទាំងអស់ ។

ដានី ៖ ចុះពូកាលពីយួនចូលមកឆ្នាំ៧៩កាលហ្នឹងដូចថា ពូរៀបរាប់ពេលហ្នឹងពូរត់មកពីកន្លែងណាទៅនៅណាអីណា?

ឃឿន ៖ កាលឆ្នាំ៧៩កាលហ្នឹងខ្ញុំទៅនៅកងចល័តព្រែកលាវ កងចល័តព្រែកលាវនៅស្រុកបរវិលនេះដល់ពេលយួនបុកមកដល់ហ្នឹងទៅ យើងចេះតែរត់ទៀតណាស់រត់រហូតចេញម៉ោអូរដូនតា ឃ្មាំងប្រហែលអ៊ូរដូនតាចេញទៅផ្លូវជាតិលេខ១០នេះមកនៅស្ទឹង នៅស្ទឹងហើយរហូតមកទៅដល់សំឡូត បានគេដកកំលាំងស្រីៗឲ្យនៅក្រោយកំលាំងប្រុសៗហ្នឹងឲ្យម៉ោមុខវិញម៉ោដល់គេចាប់បំពាក់អាវុធឆ្នាំ៧៩ហ្នឹង បំពាក់អាវុធនៅយើងខេត្តនេះខេត្តយើងតាំងម៉ែជិតអ៊ូតាគីអ៊ូតាកែនេះទៅវ៉ៃម៉ាជួរខាងត្បូងថ្មល់ រហូតពីហ្នឹងទៀតម៉ោគេចេះតែបែកគ្រសាចម៉ោរហូតយួនវ៉ៃបណ្ដើរៗ ចេះតែចាញ់រហូតៗរត់រហូរម៉ោចេញម៉ោយើងម៉ោនៅកំរងកំពង់វ៉ៃយើងម៉ោនៅ៣០នេះ ។

ដានី ៖ ៣០នៅណាទៅ?

ឃឿន ៖ ៣០យើងស្រុកសំពៅលូននេះ ដល់ម៉ោដល់ហើយគេក៏រំឡែកពួកខ្ញុំម៉ាកងធំហ្នឹងឲ្យម៉ោកងពល៤៥០នេះម៉ោនៅស្រុកម៉ាឡៃ ។

ដានី ៖ កាលដំបូងគេបំពាក់អាវុធពូនៅអូរតាគីអូរតាកែហ្នឹងពូនៅកងពលណា?

ឃឿន ៖ អាហ្នឹងអត់មានកងពលទេ ខ្ញុំនៅកងតំបន់គេហៅកងតំបន់ ។

ដានី ៖ តំបន់ណាទៅ?

ឃឿន ៖ តំបន់៣

ដានី ៖ តំបន់៣របស់ភូមិភាគពាយ័ព្យ?

ឃឿន ៖ បាទ!របស់ភូមិភាគពាយ័ព្យរបស់ រស់ ញឹម ហើយតំបន់៣ហ្នឹង ពូតុម គាត់គណៈតំបន់ពូតុមហៅ កោសារី ។

ដានី ៖ ដល់ពេលអញ្ចឹងពូចេះតែម៉ោ?

ឃឿន ៖ ចេះតែម៉ោរហូតដល់បញ្ចូនម៉ោនៅនឹងត្រឹមទិសម៉ាឡៃហ្នឹងម៉ង់ខ្ញុំ

ដានី ៖ ចុះកាលពីមុនពូដឹងពីប្រវត្តិម៉ាឡៃហ្នឹងកាលពីមុនយ៉ាងម៉េច ពូម៉ោដល់កន្លែងហ្នឹងកន្លែងស្អីគេទៅម៉ាឡៃ?

ឃឿន ៖ ទេ!តំបន់ភ្នំសុទ្ធ ព្រៃសុទ្ធ

ដានី ៖ ក្នុងស្រុកអីគេកាលពីមុន?

ឃឿន ៖ ខ្ញុំអត់ដឹងដែរ តែបើខ្ញុំថាមិនខុសពីនៅស្រុកអូរជ្រៃនេះទេ

ដានី ៖ ស្រុកអូរជ្រៅ ប៉ុន្តែអត់មានមនុស្សរស់នៅទេកាលមុន?

យឿន ៖ នៅតំបន់ហ្នឹងអត់មានទេ មានតែពួកលាវ ពួកលាវដែលនៅតាមព្រំដែនថៃហ្នឹង ដល់ពេលយើងម៉ោចូលនៅហ្នឹងវាឈប់ហានចូល ព្រៃសុទ្ធត្រង់នេះសុទ្ធតែព្រៃ ។

ដានី ៖ បើតាមពូស្មានប្រហែលនៅស្រុកអូរជ្រៅហើយមុនកងទ័ពមកដល់?

យឿន ៖ ខ្ញុំថាតំបន់នោះតំន់អូរជ្រៅហើយ ព្រោះឥឡូវវាស្ថិតនៅក្នុងស្រុកអូរជ្រៅដដែលហ្នឹង ។

ដានី ៖ បាទ!ចុះកងធំដែលពូអើយើងមកដល់ម៉ាឡៃនៅកងពលលេខ៤៥០ហ្នឹងនៅឆ្នាំណាទៅ?

យឿន ៖ ឆ្នាំ៧៩នឹងឯង ចុង៧៩ហ្នឹង នៅក្នុងកងពល៤៥០

ដានី ៖ នៅក្នុងកងពល៤៥០ ពូនៅកងធំអីគេដែរ?

យឿន ៖ ខ្ញុំនៅកងធំលេខ៥៤ តែមេកងធំហ្នឹងស្លាប់ហើយ

ដានី ៖ គាត់ឈ្មោះអីអ្នកស្លាប់?

យឿន ៖ គាត់ស្លាប់ឈ្មោះ វន មួយ គឿន

ដានី ៖ គាត់ឈឺស្លាប់ឬក៏ស្លាប់?

យឿន ៖ ត្រូវគ្រាប់មីននៅជិតនាន់ប៉ុល ពត

ដានី ៖ កងពល៤៥០តាភាពគាត់អើ?

យឿន ៖ តាភាពប្រធានកងពល កាលហ្នឹងយើងនៅជិតនាន់៤៥០ហ្នឹងយើងអត់ទាន់ទៅជាកងពលទេណាស់យើងនៅហៅ វរៈសេនាធំចំនុះកងពល៣២០ ពួកតាកននេះគាត់ជាប្រធានកងពល

ដានី ៖ គាត់នៅណា?

យឿន ៖ នៅសំពៅលូនហ្នឹងគេហៅតំបន់៣២ ។

ដានី ៖ អញ្ចឹងកាលហ្នឹងអត់ទាន់ទៅជាកងពលទេ ៤៥០ហ្នឹងនៅក្នុងកងពល៣២០របស់តាកន?

យឿន ៖ បាទ!តាកនប្រធានកងពល ។

ដានី ៖ កាលហ្នឹងកងពលមានប៉ុន្មានតំបន់ទៅដូចថានៅតំបន់ខាងម៉ាឡៃយើងនៅខាងណាទៀត?

យឿន ៖ មានវរៈសេនាធំម៉ាឡៃនេះគឺវរៈសេនា៣២០ហ្នឹង ហើយនឹងប៉ៃលិននៅក្នុងចំនុះ៣កន្លែងហ្នឹងវានៅក្នុងកងពល៣២តែមួយទេ ។

ដានី ៖ បាទ!នៅប៉ៃលិននៅក្នុងកងវរៈរសេនាធំប៉ុន្មានដែរ?

យឿន ៖ មិនដឹងប៉ុន្មានទេ

អ្នកជិតខាង ៖ ប្រហែលកងតាកាយ ។

យឿន ៖ អត់ទេមិនមែនកងតាកាយទេ កងតាកាយនៅក្រោមរបស់តាឈានទេ ។

ដានី ៖ ក្រោមតាឈាន អ៊ីឈានហ្នឹង?

យឿន ៖ បាទ!អ៊ីឈានហ្នឹង

ដានី ៖ អ៊ីយានគាត់គ្រប់គ្រងនៅប៉ៃលិន?

យឿន ៖ នៅប៉ៃលិន

ដានី ៖ ចុះខាងនេះខាងសំពៅលូន?

យឿន ៖ ខាងសំពៅលូនហ្នឹងខ្ញុំអត់សូវចំណាំច្បាស់ទេមិនដឹងជាអ្នកណាមិនដឹងជា ប៉ិតប្ញុពុតប្ញុក៏អ្នកណាទេខ្ញុំអត់សូវដឹងទេខាងនេះព្រោះខាងហ្នឹងក្នុងរយៈកាលតស៊ូពី៧៩ហ្នឹងយើងអត់អាចឆ្លងដែនគ្នាបានទេណា គាពួកខ្ញុំចូលទៅនោះក៏អត់បានដែរ ខាងនោះចូលមកនេះក៏អត់បានដែរ គេប្រកាន់បក្សរៀងខ្លួនម៉ង ហើយបើចូលទៅខុសជួរខុសអីគេចាប់យកទៅវៃចោលបណ្តោយគេថាខ្មាំងចូលស៊ើបការ ព្រោះគេអត់ដែរស្គាល់គ្នាទាំងអស់ ។

ដានី ៖ បាទ!ចុះ៨៥០របស់ពូអើតាភាពគាត់អ្នក?

យឿន ៖ តាភាព ផុនធំ ផុនតូច៣នាក់ ផុន២ណាំមានផុននោះយូនបាញ់សាប់នៅឯជើងគ្រប់

ដានី ៖ ឆ្នាំណា?

យឿន ៖ កាលបាញ់គាត់ស្លាប់នោះគាត់ត្រៀមឡើងកងពលឆ្នាំ៨០ហើយហ្នឹង ។

ដានី ៖ ឆ្នាំ៨០ហើយ?

យឿន ៖ ឥឡូវនៅផុនតូច ។

ដានី ៖ ផុតតូចគាត់ធ្វើអីឥឡូវ?

យឿន ៖ ឥឡូវនេះគាត់ផ្អាយ២ ពីមុនគាត់វរៈសេនាធំដីក្រោយមៅបានគាត់ឡើងកងពល ។

ដានី ៖ តាភាពឥឡូវគាត់នៅណា?

យឿន ៖ តាភាពឥឡូវគាត់នៅកាន់ខាងផ្នែកកងទ័ពជើងគោក ខាងព្រំដែនខាងពួកវរៈព្រំដែនមៅតំបន់ជួរព្រំដែនទល់នេះហ្នឹងគាត់ទាំងអស់គាត់មេគេបង្អស់ ។

ដានី ៖ គាត់សក្តិប៉ុន្មានហើយឥឡូវ?

យឿន ៖ ផ្កាយ២

ដានី ៖ ចុះកាលហ្នឹងអើកងទ័ពអើប៉ុន្តែមានប្រជាជនច្រើនអត់នៅមៅឡូហ្នឹងកាលឆ្នាំ៧០ជាង?

យឿន ៖ ទេប្រជាជនសុទ្ធអត់មានទេមានតែប្រពន្ធទ័ព មានប្រពន្ធយោធា បើប្រជាជនសុទ្ធសាធអត់មានទេ មានសុទ្ធតែប្រពន្ធយោធាទាំងអស់ ។

ដានី ៖ ប្រពន្ធយោធានៅម្តុំណាទៅ?

យឿន ៖ នេះនៅម្តុំនេះមៅជួរហ្នឹង

ដានី ៖ ហ្នឹងគេហៅអីទៅកន្លែងហ្នឹង?

យឿន ៖ កន្លែងហ្នឹងគេហៅ ស-១៥

ដានី ៖ ម៉េចបានគេហៅ ស-១៥អញ្ចឹង?

យឿន ៖ មិនដឹងស្រេចតែគេដាក់

ដានី ៖ ពីណាអ្នកដាក់អញ្ចឹង?

យឿន ៖ រកមនុស្សដាក់មិនឃើញមិនដឹងប៉ុនទាស់តែគេហៅស-១៥ ហៅស-១៥ដូចគេទៅ ។

ដានី ៖ កាលហ្នឹងច្រើនទេ?

អ្នកជិតខាង ៖ ច្បាស់ជាងគេនៅក្នុងភូមិដូងហ្នឹកមុនដំបូងឯង ។

យឿន ៖ ភូមិដូងកាលជំនាន់ភូមិដូងនៅមន្ទីក្នុងនោះ អាហ្នឹងវាអត់ទាន់មានប្រពន្ធទ័ពដឹគេរំឡែកប្រពន្ធទ័ពចេញមកនៅយើងស-១៥ នេះម៉ោបែកចែកជាភូមិ ។

ដានី ៖ ចុះភូមិដូងមានតាំងពី៧៩ម៉ោដែរ?

យឿន ៖ ហ្នឹងកកើតតាំងពីជំនាន់តស៊ូហ្នឹងម៉ោនិយាយរួម

ដានី ៖ នៅភូមិដូងសុទ្ធតែប្រពន្ធកងទ័ពដែរឬមានប្រជាជន

យឿន ៖ សុទ្ធតែប្រពន្ធកងទ័ពទាំងអស់អត់មានប្រជាជនសុទ្ធសាធទេ ប្រជាជនសុទ្ធសាធមែនទែនទឹមមានកាលយើងសម៉ាហរន្តកម្មហើយនេះទេ ពីមុនសុទ្ធតែប្រពន្ធកងទ័ពទាំងអស់ ។

ដានី ៖ ច្រើនទេបើតាមពូដឹង?

យឿន ៖ អើ!ច្រើនម៉ោពីប្រាសាទអីគេនោះកាលហ្នឹង ម៉ោពីភ្នំឆត្រែតទៅស-១៦-១៧ទៀតរហូតតែស-១៥ នេះកើតមុនមនុស្សអើបើខ្ញុំគិតរាប់ពាន់គ្រួសារមែនតិចៗទេ ។

ដានី ៖ តាភាពហ្នឹងគាត់គ្រប់គ្រងទាំងអស់ឬក៏មានគេគ្រប់គ្រងធំទៀត?

យឿន ៖ មាន ខាងផ្នែកប្រជាជននោះមានហុងផ្សេង ហ្នឹងគាត់ទទួលបន្ទុកក្រោយ ភាពគាត់ទទួលបន្ទុកតែទ័ពមួយមុខទេ តែចំពោះប្រពន្ធទ័ពនៅក្រោយមានគេគ្រប់គ្រងនៅក្រោយផ្សេង ។

ដានី ៖ ឈ្មោះអើ ហុង?

យឿន ៖ ហុងហ្នឹងមែនទែនគាត់កាន់នាយករដ្ឋមន្ត្រីក្រសួងការបរទេសទេ ដល់អញ្ចឹងសំភារៈអីទាំងអស់ដែលយកពីថៃបញ្ជូនម៉ោអញ្ចឹងគាត់អ្នកគ្រប់គ្រងចែកចាយឲ្យប្រពន្ធទ័ពនៅក្រោយ លុះត្រាតែប្រពន្ធហ្នឹងឈឺឬមួយក៏ម៉េចអីទៅបានគេឲ្យប្ដីម៉ោមើល ។

ដានី ៖ ចុះអ៊ឹ អៀង សារី ធ្វើអីនៅហ្នឹង?

យឿន ៖ អើស៎!អ៊ឹអៀង សារី គាត់នៅលំដាប់លើហ្នឹងទៀត ។

ដានី ៖ បើពូ ហុង ហ្នឹងគាត់អ្នកគ្រប់គ្រង?

យឿន ៖ គ្រប់គ្រងគាត់ក្រោមអ៊ឹ អៀង សារី អ៊ឹ អៀងសារី អ៊ឹ ខៀវ សំផន គាត់សុទ្ធតែអ្នកលំដាប់ៗអស់ហើយ ។

ដានី ៖ ប៉ុន្តែគាត់នៅហ្នឹងដែរឬអត់ទេ?

យឿន ៖ គាត់នៅមន្ទីក្នុង កន្លែងគាត់គេហៅមន្ទីក្នុងនៅជាប់កន្លែងសម្តេចប្រថាប់ហ្នឹង ផ្ទះគាត់ដែងក្បៀងធំៗ ។

ដានី ៖ គាត់នៅបានយូរដែរ?

យឿន ៖ គាត់នៅរហូតពីរនាក់ប្តីប្រពន្ធគាត់

ដានី ៖ ចុះពូយ៉ាងម៉េចទៅការរស់នៅពី៧៩កាលហ្នឹងដូចថាយើងកងទ័ព ហើយការរស់នៅយ៉ាងម៉េច ហូបចុក រ៉ៃអីយ៉ាងម៉េចទៅកាលហ្នឹង?

យឿន ៖ គេរ៉ៃៗទៅតាមកំណត់ផែនការបើថា តែភាគច្រើនមិនសូវរ៉ៃចេញមុខប៉ុន្មានទេ ច្រើនតែយើងរ៉ៃពីចំហៀងឈ្លប ដូចថាធ្វើទីតាំងឲ្យវាដឹងនៅចំងាយប៉ុន្មានអញ្ចឹង យើងរ៉ៃដូចរបៀបខ្វែងឆាប គេហៅរ៉ៃជិនាន់ខ្វែងឆាប រ៉ៃម៉ាប្រាវអញ្ចឹងទៅជួនណាយើងងាប់ជួនណាវាងាប់ដែរដូចតែគ្នា ប៉ុនទាស់តែត្រលប់មកវិញការហូបចុកវាពិបាកដែរ ដូចខ្ញុំនិយាយអញ្ចឹងណាម៉ាកងតូចមានគ្នា៣៣នាក់ ម៉ាពេលគេឲ្យបបរតែបីកំប៉ុងទេវាអន្តរអត់មានដឹងអញ្ចឹងសន្សំសំចៃកាល៧៩ហ្នឹង ។

ដានី ៖ អត់មានអន្តរម៉ង់?

យឿន ៖ មិនដឹងយ៉ាងម៉េច មិនដឹងជាមានមិនមានរឿងគេអ្នកផ្តល់ពីក្រោយទៅនេះអត់ដឹងទេ យើងដឹងតែថាទៅដល់យើងនោះទៅសេដ្ឋកិច្ចគេចែកឲ្យយើងអញ្ចឹងយើងហូបអញ្ចឹងទៅមិនដឹងតវ៉ាឯណា ។

ដានី ៖ ចុះកាលហ្នឹងដូចថាកងទ័ពកាលហ្នឹងដូចថាអ្នកដឹកនាំគេប្រាប់យើងថាម៉េចខ្លះដើម្បីតស៊ូអីយ៉ាងម៉េចពីគោលការណ៍ដូចថាគោលដៅគោលនយោបាយតស៊ូរ៉ៃប្រឆាំងជាមួយយួនកាលជំនាន់ហ្នឹងគេប្រាប់យើងថាម៉េចខ្លះ?

យឿន ៖ មានទាំងអស់គ្រាន់តែប្រជុំថាពួកយួនវាម៉ោឈ្លានពានទឹកដី យើងរ៉ៃការពារទឹកដីយើង ការពារប្រជាជនយើងអានេះនយោបាយគេ គេលើកអញ្ចឹងអត់មាននិយាយអីឲ្យខុស គ្រាន់តែថាខំប្រឹងតស៊ូដើម្បីរំដោះប្រទេសជាតិយើងយកពីយួនមកវិញ ព្រោះយួនវាម៉ោឈ្លានពានលេបទឹកដីលេបអីអញ្ចឹងទៅ ហើយជំនឿជឿជាក់អញ្ចឹងទៅ មានជំនឿមួយហ្នឹងឯងខំប្រឹងតស៊ូរំដោះទឹកដីហ្នឹងឯង អត់មានគិតអីទេ ។

ដានី ៖ ចុះពូមានប្រសាសន៍មុនហ្នឹងថាកាលជំនាន់នោះពេលដែលយើងរត់ឆ្នាំ៧៩ ដោយសារពូលឺគេនិយាយប្រាប់ថាបើហានតែយួនចាប់បានយួនអារក វះពោះ ច្រកថង់យ៉ាងម៉េច?

ឃឿន ៖ ហ្នឹងហើយ អាហ្នឹងខ្ញុំរត់ចេញពីកងចល័ត ហ្នឹងអត់ទាន់មានអាវុធទេណា នៅកងចល័តនៅឡើយដឹងម៉ាចំនួនវាដាច់ចិត្តថាងាប់ក៏ងាប់ទៅចូលទៅភូមិវិញក៏ចូល ម៉ាចំនួនខ្លាចនោះហើយបេះតែរត់តាមគេរហូតទៅ ហើយគេថាវៀយឯងទៅយួនអារកគ្មានសល់មួយទេដឹងអញ្ចឹងខ្លាច ។

ដានី ៖ ពីណាគេនិយាយហ្នឹង?

ឃឿន ៖ ទេ! អាហ្នឹងប្រធានកងចល័តប្រធានគ្រប់គ្រងនៅក្នុងកងចល័តយើងនេះ ដាចលនាបំភ័យយើងកុំឲ្យបែកបាក់សាមគ្គីគ្នា កុំឲ្យយើងចូលទៅក្នុងហ្នឹងណា ឲ្យយើងរត់ចេញពីស្រុក រត់ចោលស្រែចោលម៉ែចោលឪ ដើម្បីឲ្យយើងមកតស៊ូនៅនេះហើយយើងអ្នករត់តែលឺអញ្ចឹងខ្លាចលែងហានចូលហើយ ហើយទៅកាន់តែឆ្ងាយទៅៗខ្លាចលែងហានចូលបណ្ដោយ ពួកអាមេរិចក៏មិនហានទៅទេ ឡានម៉ៅដឹកក៏មិនហានទៅដែរ ។

ដានី ៖ ចុះពូកាលហ្នឹងពេលដែលយើងបែក៧៩ ពេលដែលយួនចូលហ្នឹងពូអត់ដែលនឹកឃើញថា ហ៊ឺ! អញត្រូវរត់ទៅជួបជុំឪពុកម្ដាយបងប្អូនអី កាលហ្នឹងមានចិត្តនឹកឃើញថាអញ្ចឹងដែរឬអត់ទេ?

ឃឿន ៖ ទេ! អត់មាននឹកគិតទេ ខ្ញុំនឹកឃើញចេះ! កាលខ្ញុំចេញពីស្រុកម៉ោហ្នឹងនៅឯស្រុកឯនោះហើយម្យ៉ាងស្រុកវានៅឆ្ងាយ នៅដល់កំពង់ត្រាចឯនោះ ហើយខ្ញុំមករស់នៅឯយើងតំបន់ពាយ័ព្យនេះហើយវាឆ្ងាយពេកមិនដឹងថាទៅផ្លូវណាផ្លូវណីទៀត ។

ដានី ៖ អាស់! ម៉េចបានពូមកនៅពាយ័ព្យហ្នឹង?

ឃឿន ៖ បងខ្ញុំយកម៉ោ បងខ្ញុំគាត់មករស់នៅបើកហាងនៅឯស្រុកអូរជ្រៅ គាត់មកបើកភោជនីដ្ឋាននៅហ្នឹង ហើយកូនៗទាំងអស់ខ្ញុំចេះអក្សរជាងគេហើយធំជាងគេផងគាត់ក៏យកខ្ញុំឲ្យម៉ោកាន់កាប់នៅហាងគាត់ហ្នឹង ។

ដានី ៖ អ៊ូ! តាំងពីឆ្នាំណាម៉ោអញ្ចឹង?

ឃឿន ៖ តាំងពីឆ្នាំ៧៥

ដានី ៖ អាស់! ៧៥ ម៉ោចូល....?

ឃឿន ៖ អត់ទេ! ឆ្នាំ៧០ ខ្ញុំមករស់នៅជាមួយគាត់ហ្នឹងបណ្ដោយ ។

ដានី ៖ អញ្ចឹងពូអ៊ុំមករស់នៅជាមួយគាត់នៅអូរជ្រៅហ្នឹងតាំងពីឆ្នាំ៧០ ?

យឿន ៖ បាទ!ឆ្នាំ៧០ នៅឆ្នាំ៧០បងថ្លៃខ្ញុំគាត់មកទិញផ្ទះនៅភ្នំពេញនេះ ទិញផ្ទះនៅភ្នំពេញហើយ គាត់មកបើកហាងនៅអូរជ្រៅហ្នឹង គាត់ក៏ទៅយកខ្ញុំម៉ោ ។

ដានី ៖ យកតែពូម្នាក់ទេ?

យឿន ៖ យកតែខ្ញុំម្នាក់ទេ

ដានី ៖ ប្អូនៗផ្សេងទៀតអត់ទេ?

យឿន ៖ អត់ទេ!

ដានី ៖ ដល់ពេលអញ្ចឹងពូរស់នៅហ្នឹងរហូតដល់ឆ្នាំ៧៥ទៅ?

យឿន ៖ រស់នៅរហូត រហូតទល់ឆ្នាំ៧៥ខ្មែរក្រហមវ៉ៃបែកហ្នឹង ដល់វ៉ៃបែកទៅមិនដឹងទៅណាទៀត គេក៏គៀងគរឲ្យចូលចល័តឲ្យឃើញគេវ៉ៃចោលស្រស់ម៉ង ។

ដានី ៖ ពូធ្លាប់ឃើញគេវ៉ៃចោលដែរ?

យឿន ៖ ឃើញវ៉ៃកុសៗ ទាល់តែឃើញគេហៅយកទៅវ៉ៃចោលស្រស់ៗអញ្ចឹងខ្លាចបណ្តោយ

ដានី ៖ យ៉ាងម៉េចបានជាគេហៅយកទៅវ៉ៃចោលអញ្ចឹង?

យឿន ៖ ទេ!អត់ដឹង គេថាអានេះវាងដូចសណ្តំ វាងសក្តិភូមិនាយទន់ដូចកូនទាហាន កូនគយកូនអីគេ ចេះតែថាណាស់ ហើយមើលអាណាវាងសណ្តំតិចៗអត់ទេ មិនបាច់ទៅឆ្ងាយទេ ក្បែរៗភ្លឺ ហ្នឹង គ្រាន់តែឃើញវ៉ៃខ្លាចម៉ង ។

ដានី ៖ អញ្ចឹងអ្នកវ៉ៃហ្នឹងអ្នកនៅណាទៅ?

យឿន ៖ ពួកយោធា គេហៅពួកកងទ័ពចាស់គេណាស់ ពួកកងទ័ពខ្មែរក្រហមចាស់គេដែលគេចូល រំដោះនោះណាស់ ហើយដូចពួកយើងនេះគេហៅពួក១៧មេសាគ្មានដឹងអី ហើយដូចពួកខ្ញុំអី ពួក១៧មេសាគ្មានដឹងអី ហើយអាគេអ្នកវ៉ៃហ្នឹងពួកគេតស៊ូកាលគេនៅក្នុងព្រៃនោះ មុននឹង គេមករំដោះយើងឆ្នាំ៧៥ ហើយពួកខ្ញុំពួក១៧មេសាគេថាម៉េចគឺអញ្ចឹងហើយ ដ៏ក្រលេក មើលឃើញស្រស់ៗទៀត ។

ដានី ៖ នៅណា? កាលហ្នឹងគេវ៉ៃនៅណា?

យឿន ៖ វ៉ៃមែនទែនវ៉ៃនៅតាមម៉ាដួរអន្លង់ស្រម៉ នៅស្រុកអង្គរបុរី

ដានី ៖ ឃើញទាល់ភ្នែកម៉ង? ឃើញគេវ៉ៃនៅនឹងភ្លឺស្រែ?

យឿន ៖ ឃើញឡើងខ្ញុំអត់...ដល់អញ្ចឹងទៅគេសួរខ្ញុំថា “ហែង!រៀនដល់ថ្នាក់ទីប៉ុន្មាន” ហ៊ឹម!ខ្ញុំរៀន ដល់ថ្នាក់ទី១០ខ្លាចគេណាស់ ។

ដានី ៖ ហើយម៉េចទៀតទៅ?

យឿន ៖ ដល់ហើយគេថារាងហែងនេះរាងសមតែកូនចិនទេ សណ្ដំតែធ្លាប់ជិះជាន់ធ្វើស្រែនៅលើខ្នងប្រជារាស្ត្រទេហែងអស់នេះ ។

ដានី ៖ ពីណាគេ កាលហ្នឹងគេថាអញ្ចឹង?

យឿន ៖ ហ្នឹងកាលថាខ្ញុំហ្នឹងថាមកដល់ភូមិ៥០០នេះនៅចំណងរោងគោហ្នឹងនៅក្នុងស្រុកអង្គរបុរីដែលហ្នឹង ។

ដានី ៖ អូរដល់បែក៧៥ ទៅពូមានបានទៅស្រុកវិញណា? នៅណ្នឹងរហូត?

យឿន ៖ អត់ៗមានបានទៅ

ដានី ៖ ចុះបងរបស់ពូគាត់នៅហ្នឹងដែរ?

យឿន ៖ បងខ្ញុំគាត់ចេញម៉ោគាត់មានប្ដីមានអីនៅនោះ ដល់អញ្ចឹងពួកខ្ញុំនៅកំលោះគេឲ្យចូលកងចល័ត ហើយគេអ្នកមានប្ដីមានប្រពន្ធគេនៅសហករណ៍ ។

ដានី ៖ ចុះពូអ៊ើ!ពូមានប្រសាសន៍ថាពូមាន៦នាក់ បងប្រុសអើ?

យឿន ៖ អត់ទេអា៦នាក់ទៀតនៅស្រុក ម៉ោនៅនេះមានតែខ្ញុំពីរនាក់បងស្រីខ្ញុំទេ

ដានី ៖ បងស្រីហ្នឹង មុនលឺពូថាមានបងស្រីមួយដែរ?

យឿន ៖ បងស្រីហ្នឹងម្ដាយមុន ឪពុកខ្ញុំម្ដាយពីរ

ដានី ៖ អ្អូ!ខ្ញុំយល់ហើយ អញ្ចឹងដល់ពេលបែក៧៥ ទៅបងរបស់ពូគាត់ទៅនៅសហករណ៍ទៅ ពូនៅកងចល័ត?

យឿន ៖ បាទ!យើងនៅក្មេងណាំអាយុ១៧គេឲ្យចូលកងចល័ត គេហៅកងកំលាំងទីមួយជំនាន់ហ្នឹង

ដានី ៖ ហើយម៉េចទៀតទៅ?

យឿន ៖ ចេះតែនៅកងចល័តទៀតរហូត មានអីដល់នៅកងចល័តយូរៗដល់ម៉ោអាឆ្នាំ៧៩យួនវៃរំដោះហ្នឹងក៏នេះទៅអាប្រធានកងចល័តគេថា ទៅរ៉ើយពួកយើងចូលព្រៃ ហើយចេះតែចូលតាមគេទៅ ។

ដានី ៖ ចុះពូកាលហ្នឹងពូអាយុប៉ុន្មានកាលមុនចូលកងចល័តហ្នឹង?

យឿន ៖ ខ្ញុំអាយុ១៧-១៨ឆ្នាំ

ដានី ៖ បែកមុនដំបូងពូអាយុ១៧-១៨ដល់នៅយូរទៅមានអាយុកាន់តែច្រើនទឹងគេ?

យឿន ៖ បាទ!ចេះច្រើនៗ

ដានី ៖ ចុះគេអត់មានបញ្ជូនពូទៅណាទៀតទេ?

យឿន ៖ នៅកងចល័តហ្នឹងរហូត រហូតទល់៧៩ហ្នឹងម៉ង

ដានី ៖ នៅកងចល័តនៅរោងគោខាងចារាយណ៍ហ្នឹង?

យឿន ៖ អត់ទេ!ដល់ពេលហ្នឹងគេដកខ្ញុំចេញពី ហ្នឹងគេហៅពួកកងចល័តភូមិ ដល់ហ្នឹងគេដកយើងទៅកាន់កងចល័តតំបន់ គេហៅតំបន់វិញ ។

ដានី ៖ គេហៅតំបន់អីដែរ?

យឿន ៖ គេហៅតំបន់៣ យើងនេះ តំបន់៣នៅថ្មគោល ។

ដានី ៖ អញ្ចឹងម៉ាឡៃនេះកាលជំនាន់៣ឆ្នាំនេះនៅក្នុងតំបន់៣ដែរមែនទេស៎?

យឿន ៖ មិនដឹងយ៉ាងម៉េចទេ ខ្ញុំអត់ដឹងប្រវត្តិគេ

ជិតខាង ៖ នៅតំបន់៥

ដានី ៖ ម៉ាឡៃនៅតំបន់៥?

ជិតខាង ៖ បាទ!តំបន់៥ តំបន់មានតំបន់១ តំបន់២ តំបន់៣ តំបន់៤ តំបន់៥រហូតដល់តំបន់៧ នៅភូមិភាគពាយ័ព្យ ។

យឿន ៖ អ្ហូ!អញ្ចឹងទៅខាងបវិលតំបន់៣អី?

ដានី ៖ បើនេះតំបន់៥?

ជិតខាង ៖ បាទ!ម៉ាឡៃតមបន់៥

ដានី ៖ ម៉ាឡៃស្រុកអីគេកាលជំនាន់ខ្មែរក្រហម?

ជិតខាង ៖ កាលហ្នឹងមានស្រុកអីមានតែស្រុកស៊ីសុផុននោះឯង មិនមែនស៊ីសុផុននៅខេត្តបន្ទាយមានជ័យទេណា៎ ស្រុកស៊ីសុផុននៅខេត្តបន្ទាយមានជ័យទើបតែមានក្រោយទេណា៎ ។

យឿន ៖ វាមានតែស្រុកសេរីសោភ័ណនឹងស្រុកអូរជ្រៅហ្នឹងឯងតែពីរហ្នឹង ប៉ុន្តែមិនដឹងគេបញ្ចូលខាងណាទេ ព្រោះយើងអត់ដឹង ។

ដានី ៖ ប៉ុន្តែនៅតំបន់៥?

យឿន ៖ បាទ!

ដានី ៖ ចុះពូកាលហ្នឹងពូរើកងចល័តហើយពូមានបានទៅលេងជាមួយបងស្រីពូឬក៏?

យឿន ៖ អត់ទេៗ គេអត់ឲ្យទៅលេងម៉ង

ដានី ៖ ហើយចុះគេថាពូសមតែនាយទន់ គេអត់មានរករឿងពូអីទៀតទេ?

យឿន ៖ គេនៅតែតាមដានរហូតហ្នឹង ប៉ុនទាល់កាលហ្នឹងខ្ញុំគិតតាំងចិត្តខ្លួនខ្ញុំរួចហើយ អាពួកម៉ាកខ្ញុំមួយឈ្មោះអារឿនវាកងធំខ្ញុំតែវាពួកម៉ាកខ្ញុំ អាព្រំ សារឿនវានិយាយថាជុំម៉ាយឯងកុនហើយហែងចូលបញ្ជីខ្មោចច្រើនសន្ធឹកណាស់អាយឿនអើយ ហើយខ្ញុំៗគិតហើយស្រេចថាអារឿនបើពួកអាកងឈ្លបពីរនាក់ហ្នឹងមកចាប់អញដឹងតែងាប់ហើយ ព្រោះខ្ញុំអកប្រដាល់ពីសង្គម កាលពីជំនាន់ឆ្នាំ៧០-៧៥ហ្នឹងខ្ញុំអ្នកនៅកីឡាប្រដាល់ ហើយខ្ញុំគិតនៅក្នុងចិត្តហើយ

ស្រេចថាអាវឿនបើសិនជាអាពីរនាក់ហ្នឹងមកចាប់អញ      ត្រឹមកាបិនពីរដើមនឹងដឹងតែត្រូវហើយ    មុននឹងអញងាប់អាពីរនាក់ហ្នឹងក៏អត់រស់ដែរ    ហើយខ្ញុំដឹងថាអាពីរនាក់ហ្នឹងមកចាប់វាមកតែពីរនាក់ហ្នឹងទេ  បាទ!កាបិនពីរដើម  ខ្សែមួយចំរ៉ាយ  កាបិនម្នាក់មួយដើម  មកចាប់កន្លែងក្បែរដើមត្នោតកន្លែងចិញ្ចឹងទាហ្នឹងខ្ញុំដឹង  ជិតកន្លែងកងជីខ្ញុំហ្នឹង ។

ដានី :    តែគេអត់មកចាប់ដែរ?

យឿន :    គេៗចាប់តែគេចេះតែចាប់ទៅ  តែខ្ញុំវាមិនទាន់ដល់ខ្ញុំអាចមិនទាន់ដល់អាកានូកគេទៅដឹង  តែដេកគិតរាល់តែយប់  ដេកភ័យហើយស្រេចម៉ង  ហើយវាមកចាប់អត់ដែលមកថ្ងៃទេ  ម៉ោង៧-៨យប់វាម៉ោហើយ   ដល់ម៉ោដល់អាមេកងយើងហ្នឹងៗប្រាប់ថា   ហៅយើងឲ្យទៅប្រជុំដីទៅអាមួយភ្លុង    អាមួយចង    ខ្ញុំនឹកឃើញថាភ្លុងត្រឹមកាបិនមួយដើមអីអាមួយស្ពាយនៅនឹងស្មារខ្ញុំឃើញខ្ញុំទាន់អើស៎គ្រាន់តែភ្លុងកុំរត់រកអី  បើចងខ្ញុំដឹងតែបាំងហើយ   ហើយបើបាំងបាំងទល់តែងាប់ហ្នឹងហើយបើរត់ក៏រត់ទៅណាក៏មិនរួចដែរតាមដំណើរ      បាញ់ខ្លួនឯងចោលហើយខ្ញុំគិតអស់ហើយ ។

ដានី :    ពូធ្លាប់ឃើញគេចងផ្ទាល់ភ្នែកដែរ?

យឿន :    បាទ!ទៅចាប់ជិតកន្លែងធ្វើកងជីខ្ញុំហ្នឹងនៅកន្លែងដើមត្នោតពីរដើមក្លោះហ្នឹង

ដានី :    អ្នកនៅកងចល័តជាមួយពូឬក៏យ៉ាងម៉េច?

យឿន :    ទេ!អាអ្នកចាប់ហ្នឹងគេហៅពយកនេះពួកសន្តិសុខៗយើងនៅរូង៧គេហៅអាកងសន្តិសុខ

ដានី :    អ្នកដែលត្រូវគេចាប់នៅ?

យឿន :    នៅកងចល័តជាមួយគ្នាហ្នឹង

ដានី :    អ្នកដែលនៅភូមិជាមួយគ្នាឬក៏នៅ?

យឿន :    ទេ!មិនដឹងម៉ោពីណាពីណីទេចេះតែចូលកងចល័តទៅ   សរុះម៉ោពីគ្រប់ខេត្តគ្រប់ភូមិគ្រប់ស្រុករាប់រយរាប់ពាន់នាក់នៅក្នុងកងចល័តនីមួយៗ     ម៉ាកងចល័តកន្លែងហ្នឹងគ្រាន់តែពួកប្រុសៗ៥កងធំ  ស្រីៗ៤កងធំ  ហើយក្នុងម៉ាកងធំៗវាជាង១០០នាក់ឯនោះ ។

អ្នកជិតខាង :    ប៉ុនដឹមែនទែនតាម(ស្តាប់មិនបាន)អាមេក្រុមមេកងតាគេស្អប់អ្នកណាគឺ     សម្លាប់អ្នកនោះ  ហើយគ្មានកំហុសអីទេ ។

ដានី :    ចុះអើ!ពូខ្ញុំបកមកកន្លែងមិញ    ដូចថាពីឆ្នាំ៧៩យើងនៅម៉ាឡៃដូចថាពេលកងទ័ពខ្វះអង្ករខ្វះអីគេឲ្យយើងហូបតែបបរ  ចុះដល់ពេលក្រោយមកម៉េចទៀតទៅ  បន្ទាប់ពីឆ្នាំ៧៩  ឆ្នាំ៨០?

យឿន ៖ តាំងពីហ្នឹងមៅគឺហូបបរបូរណ៍រហូត កាលហ្នឹងពួកអង្គការសហប្រជាជាតិគេជួយហើយណាស់ ហ្នឹងចាប់ពីចុង៧៩ដើម៨០គឺការហូបចុករីកចំរើនម៉ង ប៉ុន្តែការតស៊ូគឺយើងនៅតែវ៉ៃអញ្ចឹង ។

ដានី ៖ ប៉ុន្តែយើងហូបចុកហ្នឹងខាងអង្គការសហប្រជាជាតិគេជួយ?

យឿន ៖ គេជួយ ពេលគេជួយយកមៅឃើញគេដាក់កាណាដា អាមេរិច ជប៉ុន ត្រីខកំប៉ុង មានអង្ករមានអីគ្រប់បែបយ៉ាង ។

ដានី ៖ ឡានគេចូលមកដល់ម៉ងឬយ៉ាងម៉េច?

យឿន ៖ ឡានគេចូលមកដល់ភូមិយើងនេះ មៅម្តងៗស៊ីមិនអស់ផង

ដានី ៖ គេចែកឲ្យកងទ័ព?

យឿន ៖ គេចែកឲ្យកងទ័ព ចែកឲ្យប្រជាជនទាំងអស់ទូទៅ ទាំងប្រជាជនទាំងប្រពន្ធកងទ័ពទាំងអីទាំងអស់ពួកនារីដឹកជញ្ជូនអីបានហូបរបបពេលហ្នឹងហើយ ។

ដានី ៖ កាលហ្នឹងយើងហូបគ្រប់គ្រាន់បបូរណ៍ហើយ?

យឿន ៖ គ្រប់គ្រាន់មែនទែនម៉ង

ដានី ៖ ចុះពូកាលហ្នឹងនៅកន្លែងណាទីតាំងកងទ័ពរបស់ពូ?

យឿន ៖ ខ្ញុំកាលហ្នឹងនៅគ្រប់កន្លែង ជួនណាផ្លាស់ទៅនៅអូរសាឡៅ ចេញពីអូរសាឡៅមៅទៅនៅបន្ទាយទីមួយ តែខ្ញុំម៉ោបានគ្រួសារខ្ញុំនេះឆ្នាំ៨៣ហ្នឹងនៅបន្ទាយទីមួយ ។

ដានី ៖ ពូរៀបការឆ្នាំ៨៣?

យឿន ៖ បាទ!

ដានី ៖ យ៉ាងម៉េចទៅពូអាចរៀបរាប់ប្រវត្តិពេលដែលពូជួបមីង?

យឿន ៖ ទេ!កងពលរបស់កម្ពុជាប្រជាធិបតេយ្យ អ្នកណាស្រលាញ់អ្នកណាឲ្យតែយល់ព្រមគ្នាគេរៀបការឲ្យគេអត់មានហាមឃាត់យើងទេ ហើយពេលការកាលហ្នឹងអត់មានលុយទេណាគេជួយតែនំគ្នា(ហៅនំឈូកដែលយកមកពីចិនហ្នឹង) ហើយត្រីខអង្ករប៊ីចេង មីគ្រប់បែបយ៉ាងទាំងអស់ហត់តែយើងហៅគ្នាធ្វើចំអិនទៅ ហើយការគ្នាយើងហ្នឹងទៅ ។

ដានី ៖ ការយ៉ាងម៉េច?

យឿន ៖ ទេ!ផ្ទឹមអីត្រឹមត្រូវដូចយើងការធម្មតា មានអ្នកណាចាស់ជាងគេបន្តិចឲ្យរៀបឲ្យ

ដានី ៖ យើងអត់រៀបការជាគូរដូចកាលជំនាន់៣ឆ្នាំ?

យឿន ៖ អត់ទេ!យើងចង់មាំគូរៗស្រេចតែយើង

ដានី ៖ កាលហ្នឹងមីងធ្វើអីទៅ?

យឿន ៖ ពួកអ្នកដឹកជញ្ជូន

ដានី ៖ នៅហ្នឹងដែរ នៅហ្នឹងតាំងពី៧៩?

យឿន ៖ នៅតាំងពី៧៩ ដឹកជញ្ជូនដូចថាទ័ពគេនៅឯមុខចំងាយប្រហែល៣-៤-១០គីឡូអង្ករទូលទៅ វែកទៅយកទៅឲ្យដល់កងទ័ព ។

ដានី ៖ ចុះកាលហ្នឹងម៉េចបានពូហើយមីងស្គាល់គ្នាឈានដល់ការរៀបការ?

យឿន ៖ អត់ស្គាល់ទេ ឃើញម៉ងដូចថាយើងទ័ពគេម៉ោលេងនៅកន្លែងដឹកជញ្ជូនហ្នឹងណា ហើយទ័ពខាងប្រធានកងខាងវរៈដឹកជញ្ជូនគេថា ប្រសិនបើកងទ័ពមានខោអាវរហែកមានអីឲ្យពួកនារីដឹកជញ្ជូនដែលទំនេរៗជួយប៉ះបានគេអត់ប្រកាន់ទេស្រលាញ់គ្នាដូចបងប្អូនអញ្ចឹង ជួយគ្នាទៅវិញទៅម៉ោអញ្ចឹង បាទ!ដល់មៅទៅឃើញៗយើងនិយាយគេទៅ ដណ្ដឹងគេហើយ បើថាគេព្រមនឹងយើងហើយ យើងរាយការណ៍ឲ្យកងពលយើងទៅ ។

ដានី ៖ កាលហ្នឹងពូទៅដណ្ដឹងពីណាគេ?

យឿន ៖ ដណ្ដឹងខាងមេកងគេ និយាយមេកងគេហើយ និយាយខ្លួនគេផ្ទាល់ម៉ង បើថាគេមិនព្រមមេកងគេក៏មិនសម្រេចថាបង្ខំយើងដូចសម័យ៣ឆ្នាំ គេមែនថាអ៊ែឯងត្រូវតែយកមិនយកមិនបានទេអីចេះចុះអត់ទេ តាមសម្រួលបើគេថាពេញចិត្តយើង យើងពេញចិត្តគេព្រមព្រៀងរៀងខ្លួនអាហ្នឹងបានថ្នាក់លើគេសម្រេចឲ្យយើង ។

ដានី ៖ បាទ!ចុះមីងកាលហ្នឹងពូទៅនិយាយថាម៉េចខ្លះ?

យឿន ៖ គាត់សើចៗ

ដានី ៖ មីងគាត់ឈ្មោះអីដែរ?

យឿន ៖ ណាំ យឿន

ដានី ៖ មីងអាយុប៉ុន្មានហើយ?

យឿន ៖ អាយុ៥២

ដានី ៖ ចុះពូមានកូនចៅប៉ុន្មាននាក់ដែរ?

យឿន ៖ ខ្ញុំ៤នាក់

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យឿន ៖ ស្រី២ ប្រុស២

ដានី ៖ អ៊ីុធំៗអស់ហើយ?

យឿន ៖ អាបងអាយុ២៧ បន្ទាប់ម៉ោអាមួយ២៤ ២២ ហើយនឹង១៨ ១៨ពៅគេ

ដានី ៖ បាទ!ធំៗអស់ហើយ ហើយសព្វថ្ងៃពូរស់នៅភូមិអ៊ីុឫស្សីជ្រុម

យឿន ៖ បាទ!ភូមិឬស្សីជ្រុម ឃុំម៉ាឡៃ ស្រុកម៉ាឡៃ

ដានី ៖ រស់នៅហ្នឹងតាំងពីការមៅរហូត?

យឿន ៖ តាំងពី៧៩ម៉ោរហូត

ដានី ៖ អញ្ចឹងលោកពូរៀបការឆ្នាំ៨៣ហើយពូនៅធ្វើកងទ័ពទៀតឬយ៉ាងម៉េច?

យឿន ៖ បាទ!នៅធ្វើកងទ័ពដដែល

ដានី ៖ ចុះមីងនៅខាងដីកដញ្ជូន?

យឿន ៖ អត់ទេ! មានគ្រួសារហើយឈប់ហើយ អ្នកដែលមានគ្រួសារហើយគេឲ្យឈប់ហើយនៅតែផ្ទះ ។

ដានី ៖ ចុះកាលហ្នឹងពូអ៊ីពី៧៩ដល់៨០ដាងហ្នឹងដូចថា កាលហ្នឹងយើងវ៉ៃគ្នាយ៉ាងម៉េចញឹកញាប់ឬក៏យូរៗម្តងបានវ៉ៃ?

យឿន ៖ ទេ!អានេះតាមស្ថានភាពស៊ើបការ បើស៊ើបការឃើញបន្ទាយណាចន្លោះអាចវ៉ៃបាន វ៉ៃក្លាមបន្ទាយណាវាងតឹងតែងយើងទៅឆ្មក់វាសិន គេហៅថាឆ្មក់ធ្វើរបៀបខ្វែងឆាបណា ឆ្មក់លមើលកំលាំងបើថាកំលាំងវាអាចវ៉ៃកើត រៀបកំលាំងវ៉ៃបណ្តោយ បើថាកំលាំងវាវាងក្រាស់ក្រៃលដាងយើងៗមិនអាចនេះអត់ទាន់វ៉ៃទេ?

ដានី ៖ យើងមើលអញ្ចឹងដែរ?

យឿន ៖ បាទ!អានេះបច្ចេកទេសនៅលើអ្នកដឹកនាំទេ ខាងមេដឹកនាំ ។

ដានី ៖ ខាងវរៈឬក៏ខាងកងពល?

យឿន ៖ កងពលគេៗចាត់ឲ្យម៉ោវរៈសេនាធំ វរៈសេនាធំក៏រៀបម៉ោវរៈសេនាតូច តាមកងធំកងតូចទីបញ្ចប់នៅតែយុវជនដដែលហ្នឹង អ្នកស៊ើបការហ្នឹងប៉ុនទាស់គ្រាន់តែគំនិតគេអ្នកចេញម៉ោ ។

ដានី ៖ អ្ហូ!យើងទៅៗរាយការណ៍ប្រាប់គេ គេគិតមើលថាគួរធ្វើយ៉ាងម៉េចៗ?

យឿន ៖ បាទ!ជួនណាគេទៅជាមួយដែរ តែគេទៅអត់ចូលដល់សមរភូមិទេ គេគ្រាន់តែទៅស្តាប់ស្ទង់កំលាំងតាមការវាយឆ្មក់របស់យើងនឹងទៅ គេអ្នកវិភាគគេអាចវិភាគថាកំលាំងហ្នឹងប៉ុន្មានគេស្តាប់មើលកាំភ្លើងតូចកាំភ្លើងធំនៅប្រកណាខ្វះអញ្ចឹងទៅ លើកក្រោយគេស្រួលរៀបឲ្យចំៗចំណុច ហើយតាវ៉ៃហើយកម្រថាអត់បែកណាស់ តាពួកខ្មែរក្រហមវ៉ៃហើយសឹងតែថាកម្រវើរួចណាស់ តែងាប់មិនដឹងថាវាងាប់ប៉ុន្មានទេ តែយើងម៉ាភូមិៗមិនអត់ទេ ងាប់ហើយនឹងរបួស ។

ដានី ៖ ដល់ពេលស្លាប់ហើយរបួសហ្នឹងយកមកណាវិញទៅ?

យឿន ៖ យកម៉ោតាមអ្នកដែលគេមានប្រពន្ធមានអី បើយើងអត់មានទេនៅយុវជនអត់ទាន់មានទេ ដឹករណ្តាកប់ទៅ ។

ដានី ៖ ចុះអ្នករបួស?

យឿន ៖ បើអ្នករបួសដឹកយកមកព្យាបាលមន្ទីរពេទ្យភូមិដូង តែបើអ្នកស្លាប់ដែលតឹងតែងយកសព្វ មិនបានទុកចោលនៅហ្នឹងទៅ ។

ដានី ៖ ហើយចុះអ្នកដែលត្រូវរបួសធ្ងន់មកព្យាបាលនៅមន្ទីរពេទ្យភូមិដូងមិនបានគេយកទៅណា ទៀតទៅ?

យឿន ៖ មន្ទីរពេទ្យកន្លែងអ៊ឹជុំ ជឿន

ដានី ៖ នៅណាទៅ?

យឿន ៖ អ៊ឹជុំ ជឿន គាត់នៅជីថៃ អ៊ឹជុំ ជឿន ហ្នឹងពេទ្យលំដាប់ពិភពលោកហើយហ្នឹង ពេទ្យគាត់ ពេទ្យលំដាប់អាមេរិចខ្លាចហើយហ្នឹង ដល់ថ្នាក់វះបែងក្នុងខួរអាមេរិចមិនហានយកផង គាត់ ហានយកដ៏បានគាត់ពូកែណាស់គាត់រៀននៅចិន ។

ដានី ៖ ចុះអ៊ីរហូតដល់ពេលណាទៅនៅហ្នឹងរហូតដល់ពេលមានសមាហរន្តកម្មឬក៏មានវើរុសទៅណា ទៀត?

យឿន ៖ អត់ទេ អត់មានវើរុសទេនៅរហូតដល់សមាហរន្តកម្មហើយ

ដានី ៖ ចុះខាងយួន ខាងក្នុងនោះគេមានដែលវ៉ៃមកចូលដល់ហ្នឹងដែលឬអត់?

យឿន ៖ ចូល ៗ មកដល់ហ្នឹងមួយម្តង មកដល់ម៉ាជួរហ្នឹងប្រជាជនគេរត់ទៅនៅជីថៃទាំងអស់

ដានី ៖ អ៊ូ!រត់ទៅនៅជីថៃដែរ? ទៅយូរដែរឬអត់?

យឿន ៖ ទៅយូរដែរ ទៅល្មមតែស៊ើបការណ៍វ៉ៃវាបណ្តេញៗបណ្តោះមកវិញបាននាំគ្នាចូលមកនៅ វិញ តែថៃមិនដឹងជាខាងរាជរដ្ឋាភិបាល ខាងអ្នកដឹកនាំគេពិភាក្សាគ្នាម៉េចជាមួយថៃយើង អត់ដឹងរឿងគេណាស់ តែប៉ុនដល់ពេលទៅឡានថៃដឹកយកទៅ ដឹកប្រជាជនយើងទាំងអស់ យកទៅដាក់ជីថៃជ្រោគ្រាប់ដ្បូងចូលអត់ដល់ ។

ដានី ៖ គេហៅអីគេទៅជីថៃហ្នឹង?

យឿន ៖ កាលហ្នឹងគេហៅ ថ-៨៥ (ថ១ហ្នឹងថៃ)

ដានី ៖ ចុះកាលហ្នឹងមីងគាតទៅដែរ?

យឿន ៖ ទៅ

ដានី ៖ ចុះពូ?

យឿន ៖ ខ្ញុំអត់ទេ!ខ្ញុំបកមកវ៉ៃវិញ ប្តីៗអត់មានបានឲ្យនៅសុខទេ គេយកតែប្រពន្ធហើយកូនទេ

ដានី ៖ ចុះម៉េចបានយួនចូលមកដល់ហ្នឹង? មានក្លាត់អី?

យឿន ៖ គ្មានក្លាត់អីទេ វាម៉ោរបៀបវាសំភារៈវាច្រើន កាំភ្លើងធំវាច្រើនមានរត់ក្រោះ យើងអត់មានរត់ក្រោះណា ។

ដានី ៖ កំលាំងវាច្រើន?

យឿន ៖ កំលាំងវាច្រើនហើយវាមានរត់ក្រោះទៀត ដល់អញ្ចឹងទៅទិសដៅរបស់មេដឹកនាំចេះតែថាយើងដកឃ្លាសិន ដកថយៗថយលុងវាចូលមកដល់កន្លែងហ្នឹងបានយើងព័ទ្ធវ៉ៃ វាងាប់ៗច្រើនៗម៉ងយួន ងាប់ច្រើនត្រង់ថាវាចូលមកដល់កន្លែងហ្នឹងហើយវាអត់ដឹងទីតាំង ពួកហ្នឹងវាដឹងច្រកនោះទ័ពពីក្រោយដាក់មីនពីក្រោយវ៉ៃដីតែវានៅលែងបាន ។

ដានី ៖ រយៈពេលប៉ុន្មានទៅបានវាដកទៅវិញ? ទៅនៅថៃបានយូរដែរឬអត់?

យឿន ៖ ៥ - ៦ខែហ្នឹងបានវាដកឆ្ងាយពីព្រំដែនវាមិនទាន់ដកផុតទេ

ដានី ៖ ប៉ុន្តែមីងនៅដីថៃបានរយៈពេល៥ឆ្នាំ

យឿន ៖ នៅ៥ឆ្នាំហើយទៅតាំងពី៨៥ ចុះបើយួនវ៉ៃបែកឆ្នាំ៨៥ដល់ឆ្នាំ៩០យើងមកនៅនេះវិញ

ដានី ៖ ដល់ពេលម៉ោឆ្នាំ៩០អស់យួនអស់អី?

យឿន ៖ ទេវានៅជើងភ្នំនៅជួរភ្នំ នៅតែវ៉ៃអញ្ចឹងប៉ុនតែយើងយកប្រជាជនមកទុកនេះបាន ប្រពន្ធកូនទ័ពយកមកដាក់នេះវិញទាំងអស់ ។

ដានី ៖ ចុះមីនអីធ្វើម៉េចទៅដល់ពេលអញ្ចឹង?

យឿន ៖ មីនចុះលោកគ្រូមិនឃើញទេយើងនៅមានបានដីធំណាអត់ហានដោះ នេះព្រៃនេះគេអត់ទាន់ដោះឲ្យផងនេះ បើពួកស៊ីម៉ាក់មិនដោះយើងមិនហានដោះទេ នេះនៅកណ្ដាលភូមិនេះសុទ្ធតែមីន ។

ដានី ៖ រាល់ថ្ងៃហ្នឹងនៅមីននៅឡើយទេអញ្ចឹង?

យឿន ៖ បាទ!

ដានី ៖ ចុះដាំចេកដាំអីមិនប៉ះ?

យឿន ៖ អ៊េ!អត់ទេពេលយើងមករស់នៅអញ្ចឹងចេះតែរាវទៅ រាវទៅដោះខ្លួនឯង ប៉ុនទាស់នៅកន្លែងហ្នឹងវាច្រើនពេកម៉ាបន្ទាត់ហ្នឹងអត់ហានដោះ អត់ហានដោះទុកឲ្យពួកស៊ីម៉ាក់គេដោះទៅម្ដងចេះម្ដងចុះហៅគេម៉ោទៅហៅគេម៉ោទៅម្នាក់គេចេះម្នាក់គេចុះ ។

ដានី ៖ អញ្ចឹងនៅមានមីននៅឡើយទេ?

យឿន ៖ នៅ

ដានី ៖ អ៊ូ!អញ្ចឹងតាំងពីឆ្នាំយួនចូលម៉ោមានមីនច្រើនម៉េង មីនខាងយួនអ្នកដាក់ ឬក៏ខាងយើងអ្នកដាក់?

យឿន ៖ យើងផង យួនផង ដាក់ការពារខ្លួន

ដានី ៖ អញ្ចឹងមីនច្រើនចុះមានគ្រោះថ្នាក់ដែរអត់?

យឿន ៖ ម៉ុំនេះផាប់ច្រើន យកចបកាប់ដីផ្ទុះផាប់

ដានី ៖ អញ្ចឹងនៅមានដល់រាល់ថ្ងៃហ្នឹង

យឿន ៖ បាទ!នៅមានដល់រាល់ថ្ងៃហ្នឹងនៅម៉ុំមាត់អ៊ូនោះក៏នៅមាន

ដានី ៖ ចុះពីឆ្នាំ៩០ម៉ោយ៉ាងម៉េចដែរដូចថាការរស់នៅ ការហូបចុកបានគ្រប់គ្រាន់ឬក៏មានការប្រែប្រួលឬក៏នៅដដែលពេលដែលយើងមៅ?

យឿន ៖ អត់ទេនៅតែគ្រប់គ្រាន់អញ្ចឹង គ្រប់គ្រាន់រហូតដល់សមាហរន្តណកម្ម

ដានី ៖ ចុះកាលពីនៅដីថៃយ៉ាងម៉េចទៅ?

យឿន ៖ កាលនៅដីថៃក៏អត់ខ្វះខាត ការឧបត្ថមប្រពន្ធយោធាខ្លាំងណាស់

ដានី ៖ ខាងណាគេអ្នកបើកឲ្យ?

យឿន ៖ ដូចខ្ញុំនិយាយម៉េចខាងពួកអង្គការណាខ្លះទេ មិនដឹងប៉ុន្មានសិបប្រទេសសុទ្ធតែពួកអាច្រមុះស្រួចៗអញ្ចឹងមិនដឹងម៉ោពីណាខ្លះ ។

ដានី ៖ កាលហ្នឹងមានទាហានខ្មែរក្រហមនឹងទាហានខាងប៉ារ៉ា?

យឿន ៖ អត់ទេអត់មានទេ សុទ្ធតែទាហានខ្មែរក្រហមសុទ្ធ ។

ដានី ៖ ចុះសម្តេចគាត់ម៉ោឆ្នាំណា? គាត់យាងម៉ោ?

យឿន ៖ គាត់យាងម៉ោឆ្នាំ៨៤ កាលហ្នឹងសម្តេចឈ្មោះអីទេកាលហ្នឹង ។

ដានី ៖ សម្តេចសីហនុអីមែនទេ?

យឿន ៖ មិនមែនទេ ប្អូនសីហនុ

ជិតខាង៖ អើស!នរោត្តមសីហនុហើយអ្នកម៉ោហ្នឹង ឥឡូវយើងទៅវិញមុខកាលហ្នឹងពួកយួនវាម៉ោហើយណាស់ម៉ោក៏អត់ឲ្យរើព្រោះខ្លាចផ្អើលស្តេច ដ៏ខ្លាចផ្អើលស្តេច ស្តេចនៅគោរពមួយអាទិត្យនោះ ដូចនេះយើងក៏នៅរារែកៗ ។

ដានី ៖ ស្តេចគាត់យាងមកធ្វើអីនៅហ្នឹង?

ជិតខាង ៖ កត្តស្សរាកម្ម ។

ដានី ៖ កតស្សរាកម្មហ្នឹងមានន័យថាម៉េចទៅ?

យឿន ៖ ដូចគេចង់និយាយថាមកធ្វើសំណាក់ ប្រទេសណាក៏គេចូលម៉ោចងប្រជុំចង់ដោះស្រាយអី ចូលកន្លែងសាគាំងហ្នឹង ។

ដានី ៖ ចុះសាខាកងទ័ពរបស់សម្ដេចអត់នៅហ្នឹងទេមានទេ?

យឿន ៖ អត់មាន!

ដានី ៖ សុទ្ធតែខ្មែរក្រហមសុទ្ធ?

យឿន ៖ ខ្មែរក្រហមទាំងអស់

ដានី ៖ អញ្ចឹងម៉ោហ្នឹងរហូតដល់ឆ្នាំសម៉ារន្ដណកម្មឆ្នាំប៉ុន្មានទៅ?

យឿន ៖ ឆ្នាំ៩៦ ៗហ្នឹងក៏មិនទាន់មានប្រជាជនក្នុងមករស់នៅដែរ ដឹយូរទៅចេះតែស្ទាបស្ទង់មៅម៉ា គ្រួសារពីរគ្រួសារចេះតែស្រួលហ្នឹងណាស់ ស្រួល ៗ អាខ្លះគេថា ហ៊ឺ!ពួកខ្មែរក្រហមទុកចិត្ត មិនបានទេ ខ្លាចវានៅកាប់សម្លាប់មនុស្សអី ដឹយូរទៅកាន់តែស្រួលទៅ ៗ ឆ្នាំ៩៧កាន់តែ ច្រើនឡើង ៩៧-៩៨ចេះតែឡើងមករហូតសព្វថ្ងៃនេះភាគច្រើនអ្នកទីផ្សារវាសុទ្ធតែពួក អ្នកមកពីណាពីណីសុទ្ធតែពួកគេមានលុយ គេស្ពាយលុយម៉ោទិញយកម៉ង ។

ដានី ៖ អញ្ចឹងបានន័យថាពួកផ្សារឥឡូវច្រើនតែអ្នកមកពីក្នុងឯនោះទេ?

យឿន ៖ បាទ!ច្រើនតែអ្នកម៉ោពីក្នុងទេ ។

ដានី ៖ ដឹយើងនៅនេះយូរហើយមកនៅតាមភូមិវិញ?

យឿន ៖ នៅតាមភូមិ ហើយអ្នកដែលនៅផ្សារនេះ តែធម្មតាគ្នាអ្នកនៅនេះមានលុយពីណាអាអ្នក ខាងក្នុងហ្នឹងសុទ្ធតែលុយស្ពាយទាំងកាតាប ៗ ទិញយកអស់ទាំងទីប្រជុំជនផ្សារអស់ដឹអញ្ចឹង អាអ្នកគ្នានេះនៅតាមភូមិទៅនៅតាមចំការទៅ ដូចគេថា "ចិនដេញខ្មែរ ខ្មែរដេញខ្មោច" ទៅតាមហ្នឹង ចុះគេម៉ោគេមានទៅហត់នឿយអីគេម៉ោទិញតែទីផ្សារហ្នឹងប៉ុន្មានម៉ឺនប៉ុន្មាន សែនដុល្លា ។

ដានី ៖ ចុះពូអ៊ីម៉ាឡៃយើងកាលពីមុនសម៉ារន្ដកម្មហើយ ក្រោយសម៉ារន្ដកម្មមានភាពខុសគ្នាម៉េច ទៅ ដូចថាមានការខុសប្លែកម៉េចកាលពីមុន?

យឿន ៖ វាមានការខុសប្លែកគ្នាច្រើនណាស់ មិនដូចយើងជំនាន់គស៊ូ ជំនាន់គស៊ូយើងធ្លាប់រស់នៅ មានការដឹកនាំ បណ្ដឹងបង្គាប់ម៉ោជាប់ ដល់ម៉ោសម័យឥឡូវក្មេងកើតក្រោយអត់ដែលធ្វើ សង្គ្រាមនោះ បាទអញ្ចឹងវាមានការពិបាកនិយាយគ្នា ដូចលែងស្ដាប់យើងហើយម្យ៉ាង ទៀត វាកាន់តែឆ្អឹងប៉ុន្មានគ្នាទៅអាកូនគេកូនយើង អាកូនខ្លះវាគន្លងធម៌ អាកូនខ្លះវាមិន គន្លងធម៌វាដើរប្រព្រឹត្តអំពើគ្រឿងញៀនអីទៅ វាអត់ដែលប្រលូកក្នុងសង្គ្រាមវាអត់ដឹងថា ពិបាកយ៉ាងណាទេ វាដឹងតែកើតមៅធំដឹងក្ដីស្រួល ៗ ផុតពីសង្គ្រាមហើយ បើវាកើតដូចកូន

ខ្ញុំអស់នេះកើតនៅក្នុងសង្គ្រាមដែរតែវានៅតូចៗ ដល់វាធំឡើងវាផុតពីសង្គ្រាមអស់ហើយ ហ៊ីបើដូចឪពុកម្ដាយលត់ដំតាំងពីសម័យ៧៥ម៉ោម៉្លេះ សម័យកងចល័តមៅនោះ គេតំរង់អាដែករឹងម៉េចឲ្យទៅទុនអស់អីហ្នឹង ។

ដានី : បាទ!ចុះអញ្ចឹស្រុកភូមិយើងឥឡូវហ្នឹងវាមានជាផ្ទះមានដើមឈើ ចុះកាលពីមុនម៉េចដែរ?

យឿន : ពីមុនសុទ្ធតែព្រៃសុទ្ធ

ដានី : ព្រៃសុទ្ធ ចុះយើងធ្វើផ្ទះម៉េចទៅ?

យឿន : ផ្ទោះ រាវមីន កាប់រំលំព្រៃឈើកាប់កាស់កាយបន្តិចៗម្នាក់ទៅ ព្រោះកាលហ្នឹងគេកំណត់ គេកំណត់ថាអត់ឲ្យយកដីធំទេ ចែកៗគ្នាម៉ារស់សិន ហើយម្យ៉ាងយើងអ្នកតស៊ូមិនដឹងយកធ្វើអី នឹកឃើញថាយកមិនដឹងផាប់ឯណាអញ្ចឹង នឹកឃើញថាបានគ្រាន់តែម៉ាជ្រកៗទៅបាន

ដានី : ដូចជាមានលក្ខណៈជាភូមិស្រុកមានដើមឈើមានដូង ស្វា ល្ហុង ស្វាយ អីអញ្ចឹងតាំងពីពេលណាមៅ?

យឿន : អីអាហ្នឹងយើងចាប់ផ្ដើមតាំងពីឆ្នាំ៩០-៩១ដែលយើងមករស់នៅវិញ ឆ្នាំ៩១គេចាប់ផ្ដើមដាំបណ្ដើរៗ ។

ដានី : ចុះចាប់ពីឆ្នាំ៧៩មក៩០អត់មានទេ?

យឿន : អត់មានទេ!មានៗតែប្រជាជនកាលគាត់រស់នៅកាលពី៧៩ ដែលខ្ញុំថាប្រពន្ធទ័ពនោះណា អាហ្នឹងគេដាំចេក ដែលគេហៅថាដឹនាំយុត្តិសាស្ត្រ ស៊ីលឿន រត់លឿនចោល អត់ស្ដាយ

ដានី : ដាំឆាប់បានផលហើយពេលយើងចោលទៅវាអត់ស្ដាយ?

យឿន : បាទ!ប្រសិនបើយួនវ៉ៃប្រាំវម៉ោយើងប្រុយទៀតទៅ ។

ដានី : ចុះពូកាលពីសម័យមុនសមា៉រន្ដកម្មយើងមានរបបហូបចុកគ្រាប់គ្រាន់ ចុះដល់ក្រោយមៅពីឆ្នាំ៩៦យើងសមា៉រន្ដកម្មហើយកាលហ្នឹងពូនៅធ្វើកងទ័ពទៀតឬកឈប់ហើយ?

យឿន : សមា៉រន្ដកម្មហើយនៅ ខ្ញុំនៅដែរទាស់អាហ្នឹងយើងរំលាយចូលក្នុងទាហានរដ្ឋាភិបាលហើយ ទៅខាងខេមរៈភូមិន្ទហើយ អាហ្នឹងការឧបត្ថមក៏គេនៅតែឧបត្ថមឲ្យដែរ ឧបត្ថមជាលុយជាអង្ករសំរាប់ប្រពន្ធកូនក្រោយនេះ ហើយខំប្រឹងប្រែងរកខ្លួនឯងផងទៅធ្វើការថៃផងពេលមកវិញរកស៊ីប្រូតឲ្យថៃស្ទូងឲ្យថៃ កាច់ពោត បេះសណ្ដែក ឧបត្ថមក្រុមគ្រួសារយើងខ្លះ កាលហ្នឹងគេអត់មានឧបត្ថមម្ហូបអីទៀតទេណាស់ គេឲ្យតែអង្ករហើយនឹងប្រាក់ខែ ដ៏អញ្ចឹងម្ហូបយើងត្រូវដោះស្រាយខ្លួនឯង ដ៏ផុតពីហ្នឹងរហូតមកដល់សព្វថ្ងៃនេះកាន់តែថាបើអ្នកមិនរកកាន់តែអត់ ។

ដានី : ចុះពូនៅធ្វើទាហាន?

យឿន ៖ ខ្ញុំអត់ទេនេះហើយខ្ញុំកាត់ចូលសរធុនហើយ

ដានី ៖ ចូលពីឆ្នាំណាម៉ោ?

យឿន ៖ ខ្ញុំចូលសរធុនយូរហើយមិនដឹងប្រមាណទេដូចជា៩៩ខ្ញុំចូលសរធុននៅរោងចក្រ មិនទាន់កាត់ឡាយទេ តែគេឈប់ប្រើយើងហើយសម្រាប់តែដល់ខែបើកលុយៗរហូតមកដល់ឥឡូវបានគេកាត់យើងឲ្យចូលឡាយសន្តមកិច្ច ។

ដានី ៖ បាទ!ពីឆ្នាំណាចូលសន្តមកិច្ច?

យឿន ៖ ខ្ញុំចូលសន្តមកិច្ចបាន៣-៤ឆ្នាំហើយ

ដានី ៖ ចុះបើតាមពូគិតមើលយើងរស់នៅកាលពីមុនសម័យសម៉ារន្តកម្មហើយនឹងក្រោយនឹងម៉េចដែរណាស្រួលជាង?

យឿន ៖ យើងតែពិថា បើគិតតែពីស្រួលបើនិយាយឲ្យស្រួលចិត្តអាហ្នឹងថាមុនសម៉ារន្តកម្ម អាហ្នឹងយើងអត់មានខ្វល់ខ្វាយរឿងពិបាកអីរកអីទេមានតែបន្ទុំឲ្យហូប ប៉ុនទាស់ដល់យើងសម៉ារន្តកម្មយើងអត់ខ្វាចងាប់អីទេ តែការរកស៊ីចិញ្ចឹមជីវិតយើង បើថាអ្នកអត់ដីអត់អីយ៉ាប់ហ្នឹងឯងបើមិនប្រឹងគឺយ៉ាប់មុនសមារណកម្ម យើងមិនសូវប្រឹងយើងរកបន្តិចបន្តួចទៅយើងមានអង្ករមានអីទបត្តមគ្រប់បែបយ៉ាងធូរចិត្តណាស់ វាអត់មានគិតខ្វល់ខ្វាយខំប្រឹងថារកប៉ុនបានអង្ករដាំបាយស៊ីអត់ទេ ។

ដានី ៖ ឥឡូវយើងត្រូវរកខ្លួនឯងទើបបាន?

យឿន ៖ ឥឡូវយើងត្រូវរកខ្លួនឯងទើបបានស៊ី ពីមុនយើងគ្រាន់តែយ៉ាប់កំលាំងបាយ យ៉ាប់ការតស៊ូដូរជីវិតយើងយ៉ាប់មែនតែយើងអត់ខ្វាចដាច់ពោះទេ ។

ដានី ៖ ចុះក្រោយសមារណកម្មម៉ៅដីខាងរដ្ឋអំណាចគេចែកឲ្យឬក៏យើងចាប់ខ្លួនឯង?

យឿន ៖ យើងចាប់ខ្លួនឯង អត់អ្នកណាគេចែកឲ្យយើងទេ អ្នកដែលគេមិនសូវខ្វាចគេចាប់បានធំទៅយើងអ្នករៀងខ្វាចតិចទៅមនសូវហានចាប់ព្រោះខ្វាចមីនខ្វាចអី អញ្ចឹងក៏បានតិចទៅតាមរហូតមកដល់សព្វថ្ងៃនេះគេអ្នកដែលដីធំម៉ៅពីគេហានដដ ។

ដានី ៖ ចុះពូមានដីប៉ុន្មានដែរ?

យឿន ៖ ខ្ញុំមានម៉ាហត្ថដីស្រែ

ដានី ៖ អញ្ចឹងពូសព្វថ្ងៃនេះពូធ្វើស្រែធ្វើចំការឬក៏ធ្វើខ្លះទៅ?

យឿន ៖ អាគួរលើហ្នឹងធ្វើចំការ អាស្រែក្រោមទាបទំនាបលិចទឹកធ្វើស្រែ ម្ខាង៣វ៉ៃដោះស្រាយបាន

ដានី ៖ គ្រប់គ្រាន់ទេ?

យឿន ៖ ទេ!គ្រប់វាមិនគ្រប់ទេមានតែរកថែម

ដានី ៖ រកថែមពូរកអីទៅ?

យឿន ៖ ទៅធ្វើស៊ីឈ្នួរគេហ្នឹងគេហៅធ្វើអីធ្វើហ្នឹងទៅ

ដានី ៖ ស៊ីឈ្នួរនៅក្នុងស្រុកយើងឬក៏ទៅថៃ?

យឿន ៖ រកនៅស្រុកយើងហ្នឹង ទៅថៃខ្ញុំអត់ទៅទេឥឡូវ តាំងពីមានរឿងជាមួយទាហានថៃម្ដងម៉ោ ខ្ញុំមិនដែលទៅទេ ។

ដានី ៖ ពូមានរឿងជាមួយទាហានថៃ?

យឿន ៖ ដូចថាវាមើលងាយយើង យើងទ្រាំមិនបាន អ្នកដែលគេមិនសូវនេះគេចេះតែទៅធ្វើទៅ មានអី តែដូចខ្ញុំវាមនុស្សដឹងអាទាហានថៃអាក្មេងៗយកឈើមកគោះក្បាលរាប់មួយអញ្ចឹងខ្ញុំ នឹកឃើញអត់ចិត្ត សុខចិត្តធ្វើការឲ្យខ្មែរយើងវិញវាថ្លៃថ្នូរជាង ទោះបីយើងចាយប្រាក់ខ្មែរ មែនក៏ឥឡូវហ្នឹងមានតំលៃស្មើនឹងថៃដែរខ្មែរយើងឥឡូវម៉ោថ្ងៃមួយម៉ឺនពីរពាន់ មួយម៉ឺនបី ពាន់អីនោះណា ហើយថៃមួយរយបាតបើគិតដូរកាត់ទឹកចុះឡើងៗមិនខុសគ្នាប៉ុន្មានទេ ។

ដានី ៖ ពិបាកដែរអញ្ចឹងនោះក្រោយពីការសមារន្តកម្មហើយ យើងត្រូវប្រឹង?

យឿន ៖ ត្រូវប្រឹងដោយខ្លួនឯងហើយគ្មានអ្នកណាជួយទៀតទេ បើអត់ប្រឹងទេដាច់បាយដាច់ម្ហូប

ដានី ៖ ចុះពូមានដែលបានទៅលេងស្រុកកំណើតដែរឬអត់?

យឿន ៖ ទៅខ្ញុំទៅលេងប្អូនៗខ្ញុំនៅឯស្រុក

ដានី ៖ បាទ!ធ្លាប់ទៅបានប៉ុន្មានដងដែរ?

យឿន ៖ ខ្ញុំទៅស្រុកខ្ញុំបានមួយដង

ដានី ៖ ឆ្នាំណា?

យឿន ៖ អើស៎មិនឆ្នាំណាហើយទេភ្លេចបាត់ហើយខ្ញុំ

ដានី ៖ ទៅបានជួបជុំបងប្អូនដែរ?

យឿន ៖ បាទ!ទៅបានជួបជុំបងប្អូនខ្ញុំទាំងអស់

ដានី ៖ បងប្អូនពូនៅឯស្រុកទាំងអស់គ្នា?

យឿន ៖ នៅឯស្រុកទាំងអស់គ្នាហ្នឹងនៅ៣នាក់ ៤នាក់អាមួយទៅនៅភ្នំពេញ ហើយមីមួយទៀតមី ពៅសេរីសសិលា(នៅសហរដ្ឋនៅក្រៅ) គ្រាន់តែដឹងដំណឹង គេតែការទំនាក់ទំនងអី អត់មានទេ ។

ដានី ៖ គាត់អត់ដែរមកលេង?

យឿន ៖ អត់ទេ បើខ្មោចបងស្រីខ្ញុំហ្នឹង កាលគាត់នៅរស់គាត់ខស្សរាហ៍ផ្ដល់មកឲ្យខ្ញុំដែរ

ដានី ៖ ចុះពូទៅស្រុកបានប៉ុន្មានថ្ងៃដែរ?

យឿន ៖ ខ្ញុំទៅបានម៉ាអាទិត្យដែរ

ដានី ៖ កាលហ្នឹងឪពុកម្ដាយពូគាត់ស្លាប់អស់ហើយ?

យឿន ៖ ស្លាប់អស់ហើយគាត់ស្លាប់តាំងពី៧៩នោះ

ដានី ៖ ទាំងពីរនាក់ទាំងឪពុកទាំងម្ដាយ?

យឿន ៖ ឪពុកស្លាប់៧៥ ម៉ែ៧៩

ដានី ៖ គាត់ឈឺទាំងពីរនាក់?

យឿន ៖ បាទ!ឈឺចាស់ទៀតនោះ

ដានី ៖ ចុះពូដូចថាយើងបែកពីស្រុកយូរអញ្ចឹង ដល់ពេលយើងទៅស្រុកមានអារម្មណ៍យ៉ាងម៉េចដែរ?

យឿន ៖ ទេ!គ្រាន់តែឃើញគេធម្មតា គេរីកចំរើនរបស់ហើយនៅស្រុកគេ

ដានី ៖ ពូបងប្អូនអីបែកគ្នាយូរអីដូចថាអារម្មណ៍បងប្អូនអីយើងនៅស្និតស្នាលដូចកាលនៅពីក្មេងធ្លាប់រស់នៅជាមួយគ្នាឬក៏ដូចថាយើងបែកគ្នាយូរហើយយើង?

យឿន ៖ ទេការស្និតស្នាលជាមួយគ្នាវាស្និតនោះឯងស្និតម៉ាវយៈដូចថា យើងទៅយូរពេកនឹកគ្នាអញ្ចឹង ដុតពីហ្នឹងដល់ពេលមានកូនចៅរៀងខ្លួនទៅគេចេះគិតពីរឿងកូនចៅដូចតែគ្នាទៅ ។

ដានី ៖ ចុះពូទៅលេងស្រុកកំណើតដូចថាយូរអីពូមាននឹកមកដល់ស្រុកភូមិពូនៅនេះវិញឬអត់ទេ?

យឿន ៖ បាទ!នឹកមកដល់នេះវិញព្រោះខ្ញុំដូចថាគ្មានស្រុកកំណើតអីនៅស្រុកនោះទៀតទេ គិតថានៅកន្លែងនេះថាជាស្រុកកំណើតខ្លួនឯង ។

ដានី ៖ អារម្មណ៍នៅនេះដូចថាប្រពន្ធ កូនចៅនៅនេះហើយញាតិមិត្តជិតខាងរាប់អានស្និតស្នាលនៅនេះ បើនៅស្រុកយើង យើងបែកគ្នាយូរហើយ?

យឿន ៖ បាទ!បែកគ្នាយូរហើយគ្រាន់តែឃើញគ្នាមួយភ្លែតហ្នឹង តែបើចាត់ទុកៗស្រុកកំណើតនៅនេះ អារឿងស្រុកកំណើតនៅនោះវា ។

ដានី ៖ ដូចជាស្រុកភូមិពូកកើតនៅនេះទៅហើយ?

យឿន ៖ មើលកូនៗឡើងអាយុ២០-៣០កូនខ្លះឡើង៣០ផ្ងាយហើយវាមានដឹងស្រុកកំណើតវាណា វាដឹងតែស្រុកកំណើតវានៅម៉ាឡៃ ។

ដានី ៖ ហើយចុះបងប្អូនពូមានដែលមកលេងនេះដែលអត់?

យឿន ៖ ម៉ោ ម៉ោលេងម្នាក់២ដង តែឥឡូវគេធូរធារណាស់ប្អូនៗគេចេញចូលទៅយួនដួញគ្រឿងសមុទ្រ ។

ដានី ៖ ទៅខាងហ្នឹងជិតខាងយួនដែរ?

យឿន ៖ ផ្ទះវានៅព្រៃចាកហ្នឹងម៉ងជាប់ព្រំប្រទល់ឆ្លងព្រែកម្ខាងម្នាក់

ដានី ៖ ចុះអ្នកជិតខាងពូកាលពីក្មេងៗ ម៉េចដែរ នៅស្រុកភូមិ?

យឿន ៖ អត់ទេអត់បានជួបទេ ខ្ញុំទៅៗ តែចូលលេងផ្ទះប្អូនខ្ញុំ តែប្អូនគេថានៅ

ដានី ៖ ចុះពូសព្វថ្ងៃពូមានដែលលឺពត៌មានទាក់ទងរឿងតុលាការអីដែលអត់ តុលាការគេកាត់ទោស មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម?

យឿន ៖ ទេ!ខ្ញុំដែលបានមើលឃើញទូរទស្សន៍អគ្គាលកាត់ទោសលោកឌុចនោះឯង ក្រៅពីនោះខ្ញុំអត់ ដែលបានមើលទៀតទេ ។

ដានី ៖ កាត់ទោសលោកឌុចពូមើលដែរអញ្ចឹង នៅនេះមានទូរទស្សន៍មើលដែរ?

យឿន ៖ បាទ!

ដានី ៖ ពូយល់ឃើញម៉េចដែរតុលាការហ្នឹង

យឿន ៖ ទេ!មិនដឹងយល់យ៉ាងម៉េចទេខ្ញុំអត់ហានថាគេទេ តាមច្បាប់គេត្រូវធ្វើ ជារឿងរបស់ច្បាប់ តុលាការ ។

ដានី ៖ បាទ!ដូចថាតាមយោបល់ពូផ្ទាល់ ពូគិតថាតុលាការហ្នឹងត្រឹមត្រូវដែរឬក៏មិនត្រឹមត្រូវមូល ហេតុអី តាមយោបល់ពូផ្ទាល់?

យឿន ៖ ទេ!ចំពោះខ្ញុំ ខ្ញុំមិនហានថាទេរឿងការងារនយោបាយរបស់គេអ្នកអញ្ចឹងៗ

ដានី ៖ ចុះពូកាលពូរត់៧៩ពូមានដែលធ្លាប់បានជួយអ្នកណាផ្សេង ដែលពេលរត់ទៅជាមួយគ្នា ពេល ពេលហ្នឹងដូចថាមានបញ្ហាឈឺស្កាត់ធ្លាប់ជួយយកអាសារគេ ឬក៏ធ្លាប់ឲ្យបាយទឹក អីឲ្យគេអ្នក អត់បាយតាមផ្លូវពេលរត់ហ្នឹងមានដែរឬអត់ទេ?

យឿន ៖ ៧៩ដូចគ្នាវាអត់ទាំងអស់គ្នាហ្នឹង គ្មានអ្នកណាជួយអ្នកណាបានទេបើមានគាជួយ ជួយសែង បើថាមានទឹកជួយបាន បើជួយជាបាយជាអង្ករវាអត់ដូចតែគ្នាហ្នឹង ដើរចង់ងាប់មានតែខ្លួន បបរដូចខ្ញុំថាអញ្ចឹងបបរមួយក្តាប់លាយជាមួយហ្នឹងអាគុលល្ហុង គុលចេក ម្នាក់ៗសំលឹង ឃើញតែព្រះអាទិត្យមិនដឹងឯណាលិចឯណាកើតមិនដឹងថ្ងៃណាងាប់ទេ (ខ្ញុំចង់និយាយថា អញ្ចឹង) ដើរៗ ទៅអ្នកខ្លះដើរៗ ទៅដេកងាប់ក៏មាន ។

ដានី ៖ ចុះបើតាមពូនេះអ៊ើពូកាលពីសម័យ៣ឆ្នាំពូពិបាកដែរកាលហ្នឹង?

យឿន ៖ សម័យ៣ឆ្នាំខ្ញុំពិបាកដែលហ្នឹង ៣ឆ្នាំហ្នឹងខ្ញុំដូចខ្ញុំថាអញ្ចឹងខ្ញុំនៅតែចាំថ្ងៃគេយកទៅវៃចោល ហ្នឹងឯង ។

ដានី ៖ ពូធ្លាប់ឃើញគេសម្លាប់មនុស្សដែរ ពូជឿថាកាលជំនាន់ហ្នឹងដឹងតែមានគេសម្លាប់មនុស្ស?

យឿន ៖ អេ៎ស! សម្លាប់ឃើញច្បាស់ដឹងតែសម្លាប់ហើយ មិនដឹងជាខុសស្អីៗ អត់ដឹងកំហុសគេទេ គ្រាន់ឃើញភុសផស់ទៅទុកចោលនៅហ្នឹងទៅ ។

ដានី ៖ ចុះដល់ពេលពូមកនៅនេះពូមកនៅជាមួយពួកកងចំរុះដូចថាមានការខុសគ្នាកាលពីជំនាន់ពតឆ្នាំ ដូចថាពីហ្នឹងម៉ោយើងរត់មកនៅនេះទាំងអស់គ្នាទាំងគ្រប់កងគ្រប់ផ្នែកហើយយើងនៅ?

យឿន ៖ អត់ទេបែកគ្នា គេបំបែកៗគ្នាអស់ បំបែកគ្នាអស់ទៅគេឲ្យមកនេះតែម៉ាកងធំទេ កងធំហ្នឹងក៏មានអ្នកស្លាប់បណ្តើរៗ ឥឡូវក៏នៅរស់ច្រើនដែរ ពួកខ្ញុំអ្នកមោ៉ពីចល័តហើយក៏មានកូនមានចៅរៀងៗខ្លួនអស់ទៅទាំងស្រីទាំងប្រុស ។

ដានី ៖ ចុះមកដល់នេះដូចថាការអប់រំ ការដឹកនាំអីយ៉ាងម៉េចទៅមានការខុសប្លែកពីពតឆ្នាំម៉េចទៅ?

យឿន ៖ ទេ! វាខុសៗហើយខុសគ្នាទាំងស្រុងម៉ង់ ព្រោះឥឡូវយើងដឹកនាំតែរឿងអាវុធហើយសម័យពតឆ្នាំដោះស្រាយដឹកនាំពីរឿងចប ខុសគ្នាអញ្ចឹង អាចបនោះវេទនាម្យ៉ាង ហើយដល់អានេះយកអាយុជីវិតទៅស្លាប់ទៀត អាមួយគ្រាប់កាំភ្លើងអាមួយចបទោះបីជាយើងហូបបបរតិចតួចវាមិនសូវអី ហើយឥឡូវនេះហូបបបរដូចគ្នាដែរតែយកអាយុជីវិតទៅប្តូរសមរភូមិទៀត វារឹតតែយ៉ាប់លើសពីសម័យពតឆ្នាំទៀត តែអានេះយើងបើងាប់ៗយកអាវុធទៅធ្វើសង្គ្រាម បើយើងងាប់ៗឲ្យអស់ចិត្តតែបើសម័យពតឆ្នាំនោះអត់មានអាវុធអីទេមិនដឹងខឹងឯងពីអង្គាល់ហៅវ៉ៃចោលហើយទៅបាត់ទៅ មិនដឹងជាមានអីតវ៉ា ។

ដានី ៖ ចុះមីងអ្នកស្រុកកំណើតនៅខាងណាដែរ?

មីង ៖ ខ្ញុំនៅកំពង់ស្ពឺ

ដានី ៖ នៅកំពង់ស្ពឺទេ នៅជិតភ្នំពេញដែរ?

មីង ៖ ចា៎!

ដានី ៖ នៅស្រុកណាកំពង់ស្ពឺ?

មីង ៖ នៅភ្នំស្រួច

ដានី ៖ បាទ! អញ្ចឹងខ្ញុំអរគុណច្រើនពូ ដែលបានជួយសំណេះសំណាលជាមួយនឹងខ្ញុំ ។

យឿន ៖ បាទ!ៗ

«ចប់»